**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ ......៣០១...... ក.ប/ស.និ.ប្ប

## សេចក្តីជូនដំណឹង

## ស្តីពីការប្រឡងជ្រើសរើសគរុនិស្សិតបច្ចេកទេសកម្រិតឧត្តម និងមូលដ្ឋាន

យោង : - លិខិតលេខ ៦៤៦ ស.ជ.ណ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

- ផែនការតម្រូវការគ្រូបច្ចេកទេសសម្រាប់ឆ្នាំសិក្សា២០១៤-២០១៥ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណៈជនឱ្យបានជ្រាបថា ក្នុងឆ្នាំសិក្សា២០១៤-២០១៥ ក្រសួងត្រូវការប្រឡងជ្រើសរើស និងបណ្តុះបណ្តាលគរុនិស្សិតបច្ចេកទេសកម្រិតឧត្តមចំនួន ២៥០ នាក់ តាមប្រព័ន្ធបណ្តុះបណ្តាល (សញ្ញាបត្របរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស+១) និងមូលដ្ឋានចំនួន ៥០ នាក់ តាមប្រព័ន្ធបណ្តុះបណ្តាល (សញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស/ឯកទេស+១) ឱ្យចូលរៀននៅវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេសដែលមានជំនាញដូចខាងក្រោម ៖

### ក. កម្រិតឧត្តម

| | | | | | |
|---|---|---|---|---|---|
| ១. | ព័ត៌មានវិទ្យា | ចំនួន ១០ នាក់ | ១២. | បសុព្យាបាល/វេជ្ជសាស្ត្រសត្វ | ចំនួន ១៧ នាក់ |
| ២. | គ្រប់គ្រង | ចំនួន ០២ នាក់ | ១៣. | ក្សេត្រសាស្ត្រ | ចំនួន ១២ នាក់ |
| ៣. | គណនេយ្យ | ចំនួន ១០ នាក់ | ១៤. | វារីវប្បកម្ម/ជលផល | ចំនួន ០៦ នាក់ |
| ៤. | ម៉ាឃីតធីង | ចំនួន ០២ នាក់ | ១៥. | បរិក្ខារត្រជាក់ | ចំនួន ១៨ នាក់ |
| ៥. | ធនាគារ និងហិរញ្ញវត្ថុ | ចំនួន ០២ នាក់ | ១៦. | យន្តសាស្ត្រថេរយន្ត/មេកានិចទូទៅ | ចំនួន ៣១ នាក់ |
| ៦. | ភាសាអង់គ្លេស | ចំនួន ១០ នាក់ | ១៧. | យន្តសាស្ត្រទូទៅ/វិស្វកម្មលោហៈ | ចំនួន ១០ នាក់ |
| ៧. | នីតិសាស្ត្រ | ចំនួន ០២ នាក់ | ១៨. | គណិតវិទ្យា | ចំនួន ១០ នាក់ |
| ៨. | សំណង់ស៊ីវិល | ចំនួន ៣០ នាក់ | ១៩. | រូបវិទ្យា | ចំនួន ០៥ នាក់ |
| ៩. | អគ្គិសនី | ចំនួន ៣៦ នាក់ | ២០. | គីមីវិទ្យា | ចំនួន ០៧ នាក់ |
| ១០. | អេឡិចត្រូនិច | ចំនួន ២០ នាក់ | ២១. | ជីវវិទ្យា | ចំនួន ០១ នាក់ |
| ១១. | ស្ថាបត្យកម្ម | ចំនួន ០១ នាក់ | ២២. | អក្សរសាស្ត្រខ្មែរ | ចំនួន ០៤ នាក់ |

### ខ. កម្រិតមូលដ្ឋាន

| | | | | | |
|---|---|---|---|---|---|
| ១. | សំណង់ស៊ីវិល | ចំនួន ១០ នាក់ | ៥. | គ្រឿងយន្តកសិកម្ម | ចំនួន ០២ នាក់ |
| ២. | អគ្គិសនី | ចំនួន ០៨ នាក់ | ៦. | យន្តសាស្ត្រថេរយន្ត/មេកានិចទូទៅ | ចំនួន ១៤ នាក់ |
| ៣. | អេឡិចត្រូនិច | ចំនួន ០៥ នាក់ | ៧. | យន្តសាស្ត្រទូទៅ/វិស្វកម្មលោហៈ | ចំនួន ០៦ នាក់ |
| ៤. | បរិក្ខារត្រជាក់ | ចំនួន ០៥ នាក់ | | | |

## ១. លក្ខខណ្ឌជ្រើសរើស

ជ្រើសរើសក្នុងចំណោមបេក្ខជនដែលមានសញ្ជាតិខ្មែរ ជីវប្រវត្តិច្បាស់លាស់ សុខភាពល្អ កាយសម្បទាមាំមួន និងមានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣០ ឆ្នាំ គិតមកដល់ថ្ងៃប្រឡង (ជនពិការត្រូវបានលើកទឹកចិត្ត) ។ ចំពោះគរុនិស្សិតបច្ចេកទេសកម្រិតឧត្តម បេក្ខជនត្រូវមានសញ្ញាបត្រទាបបំផុតត្រឹមសញ្ញាបត្របរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស ឬសញ្ញាបត្រដែលមានតម្លៃស្មើ និងមានឯកទេសសមស្របតាមជំនាញដែលសាមីជនជ្រើសរើស ។ ចំពោះគរុនិស្សិតបច្ចេកទេសកម្រិតមូលដ្ឋាន បេក្ខជនត្រូវមានសញ្ញាបត្រទាបបំផុតត្រឹមសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស/ឯកទេស ឬសញ្ញាបត្រដែលមានតម្លៃស្មើ និងមានឯកទេសសមស្របតាមជំនាញដែលសាមីជនជ្រើសរើស ។

ក្រោយពីការប្រឡងបញ្ចប់ការសិក្សាជាប់ជាស្ថាពរ គរុនិស្សិតទាំងអស់ត្រូវទទួលបានក្របខណ្ឌចូលបម្រើការងារក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក្នុងឋានៈជាគ្រូបច្ចេកទេសកម្រិតឧត្តម ឬជាគ្រូបច្ចេកទេសកម្រិតមូលដ្ឋាន។

(ការបែងចែកកន្លែងធ្វើការ នឹងធ្វើការជ្រើសរើសដោយផ្អែកទៅលើលទ្ធផលប្រឡងបញ្ចប់ការសិក្សា)

## ២. ការប្រឡងជ្រើសរើស

ក. កាលបរិច្ឆេទលក់ពាក្យ និងទទួលពាក្យសុំចុះឈ្មោះប្រឡង : ចាប់ពីថ្ងៃប្រកាសផ្សាយដំណឹងនេះ រហូតដល់ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៤ វេលាម៉ោង ១១:០០ ព្រឹក ជាកំណត់ ។

ខ. សម័យប្រឡង : ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៤

គ. វិញ្ញាសាប្រឡង :

- កម្រិតឧត្តម :
  - វិញ្ញាសាវប្បធម៌ទូទៅ រយៈពេល ២ ម៉ោង មេគុណ ១
    (វិញ្ញាសាមួយសម្រាប់គ្រប់មុខវិជ្ជាឯកទេស)
  - វិញ្ញាសាមុខវិជ្ជាឯកទេស រយៈពេល ៣ ម៉ោង មេគុណ ២
- កម្រិតមូលដ្ឋាន :
  - វិញ្ញាសាវប្បធម៌ទូទៅ រយៈពេល ២ ម៉ោង មេគុណ ១
    (វិញ្ញាសាមួយសម្រាប់គ្រប់មុខវិជ្ជាឯកទេស)
  - វិញ្ញាសាមុខវិជ្ជាឯកទេស រយៈពេល ២ ម៉ោង មេគុណ ២

(ចំពោះបេក្ខជនដែលមានពិន្ទុសរុបក្រោមមធ្យមភាគ មិនត្រូវបានយកមកដាក់ក្នុងការជ្រើសរើសនោះទេ)

## ៣. ទីកន្លែងទទួលពាក្យ និងប្រឡង

ក. កន្លែងទទួលពាក្យ: វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស ដែលមានទីតាំងនៅតាមបណ្តោយមហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ (ច្រកចូលខាងកើតរបងវត្តទឹកថ្លា)

ខ. មណ្ឌលប្រឡង: វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស។

## ៤. សំណុំលិខិតរបស់បេក្ខជន

បេក្ខជនត្រូវបំពេញពាក្យសុំចុះឈ្មោះ និងសំណុំលិខិតទាំងអស់ដោយផ្ទាល់ដៃ

១. ពាក្យសុំចុះឈ្មោះប្រឡងមានបិទតែមប្រៃសនីយ៍ ៦០០៛ ..........................................០១ ច្បាប់

២. សញ្ញាបត្រ (ថ្នាក់ទីបញ្ចប់ម៉ឺនថ្នាក់បឋមភូមិ ឬមធ្យមសិក្សា និងប្រតិបត្តិការ ខេត្ត-ក្រុង ឬរាជធានី-ខេត្ត) ឬវិញ្ញាបនបត្របណ្តោះអាសន្ន ត្រូវបញ្ជាក់ទទួលស្គាល់ដោយស្ថាប័នគ្រប់គ្រងគ្រឹះស្ថានសិក្សា ..........................................០១ ច្បាប់

៣. ជីវប្រវត្តិសង្ខេបមានបិទរូបថត ៤ x ៦ ..........................................០១ ច្បាប់

៤. សាលាកបត្រឯកត្តជន (មានបិទរូបថត ៤ x ៦) ..........................................០១ ច្បាប់

៥. វិញ្ញាបនបត្រសុខភាព និងកាយសម្បទា (ក្រោយពេលប្រឡងជាប់ជាស្ថាពរ)..........០១ ច្បាប់

៦. លិខិតធានារបស់ឪពុកម្តាយ ឬអាណាព្យាបាល ..........................................០១ ច្បាប់

៧. កិច្ចសន្យាបម្រើការងារក្នុងក្របខណ្ឌជាគ្រូបច្ចេកទេស ..........................................០១ ច្បាប់

៨. រូបថតថ្មី ថតចំពីមុខ គ្មានពាក់មួក គ្មានពាក់វ៉ែនតា ទំហំ ៤ x ៦.......................... ០១ សន្លឹក

៩. លិខិតបញ្ជាក់ទោស (ក្រោយពេលប្រឡងជាប់ជាស្ថាពរ) ..........................................០១ ច្បាប់

១០.បង្កាន់ដៃសុំសិទ្ធិប្រឡង..........................................០១ ច្បាប់

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ២០១៤

រដ្ឋមន្ត្រី

អ៊ិត សំហេង

**ចម្លងជូន:**

- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត
- គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈក្រោមឱវាទ "ដើម្បីផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ